ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ៨២៧ សចណ៥.អគ

**គោរពជូន**

**ឯកឧត្តម លោកជំទាវ**

**ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ** : ការចាត់តំណាងរបស់ក្រសួង ស្ថាប័ន ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

**យោង** : សារាចរណែនាំលេខ ១៣ សរណន ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាល ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា : កន្លងមកទីស្តីការគណៈរដ្ឋមន្ត្រីបានសង្កេតឃើញមានក្រសួង ស្ថាប័នមួយចំនួន បានខិតខំយកចិត្តទុកដាក់អនុវត្តតាមស្មារតីនៃសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ១៣ សរណន ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការចាត់តាំងតំណាងរបស់ក្រសួង ស្ថាប័ន ចូលរួមក្នុងកិច្ចប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រី ។ ទន្ទឹមនឹងនេះ ក៏មានក្រសួង ស្ថាប័នមួយចំនួនទៀត នៅពុំទាន់អនុវត្តបានត្រឹមត្រូវតាមស្មារតីនៃសារាចរណែនាំខាងលើនៅឡើយ ។

ដើម្បីពង្រឹងយន្តការ នៃអង្គប្រជុំលើកទី ១ និងអង្គប្រជុំអន្តរក្រសួង នៅទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ សូមឯកឧត្តម លោកជំទាវ មេត្តាជ្រាបនូវគោលការណ៍ដូចខាងក្រោម ៖

ក- អង្គប្រជុំទី ១ គឺជាការប្រជុំពិគ្រោះយោបល់ ដែលក្រសួង ស្ថាប័នសាមីត្រូវពិភាក្សា ផ្លាស់ប្តូរយោបល់ជាមួយក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាល ដើម្បីពិនិត្យលើទិដ្ឋភាពនយោបាយ ទិដ្ឋភាពច្បាប់ ទិដ្ឋភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងផ្នែកទម្រង់ ខ្លឹមសារ ពាក្យបច្ចេកទេស អក្ខរាវិរុទ្ធ របស់សេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលក្រសួងស្ថាប័នសាមីបានស្នើ ។ ដើម្បីឱ្យការពិភាក្សាទទួលបានលទ្ធផលល្អ ក្រសួង ស្ថាប័នសាមីត្រូវចាត់តំណាង ថ្នាក់រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ និងមន្ត្រីជំនាញ ដែលមានសមត្ថភាព និងយល់ដឹងច្បាស់អំពីការងារពាក់ព័ន្ធ ទៅចូលរួម ដើម្បីការពារសេចក្តីព្រាងអត្ថបទ ដែលជាសំណើរបស់ក្រសួង ស្ថាប័នផ្ទាល់ ។

ខ- អង្គប្រជុំអន្តរក្រសួង គឺជាការប្រជុំសម្របសម្រួលមតិយោបល់ របស់ក្រសួង ស្ថាប័នដែលស្នើសេចក្តីព្រាងអត្ថបទ និងក្រសួងស្ថាប័នដែលពាក់ព័ន្ធ ។ ដើម្បីឱ្យការងារនេះទទួលបានលទ្ធផលល្អ ក្រសួងស្ថាប័នសាមី និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវចាត់តំណាងទៅចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សា និងសម្រេចសេចក្តីព្រាងអត្ថបទចុងក្រោយសម្រាប់ដាក់ឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដូចខាងក្រោម ៖

- ចំពោះក្រសួង ស្ថាប័នសាមី ត្រូវចាត់សមាជិករាជរដ្ឋាភិបាល អមដោយអនុរដ្ឋលេខាធិការ និងមន្ត្រីជំនាញដែលមានសមត្ថភាព និងយល់ដឹងច្បាស់អំពីការងារពាក់ព័ន្ធ ទៅចូលរួមជាចាំបាច់ ដើម្បីការពារសេចក្តីព្រាងអត្ថបទឱ្យមានប្រសិទ្ធភាព ។

- ចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចាត់តំណាងថ្នាក់រដ្ឋលេខាធិការ ឬ អគ្គនាយកដែលមានសមត្ថកិច្ច និងយល់ដឹងច្បាស់អំពីការងារពាក់ព័ន្ធ ទៅចូលរួមប្រជុំ ។

ដើម្បីឱ្យការប្រជុំដំណើរការទៅមុខដោយរលូន តំណាងចូលរួមប្រជុំ ត្រូវចូលរួមប្រជុំតាំងពីដើមរហូតដល់ចប់សេចក្តីព្រាងអត្ថបទ ។ ក្នុងករណីមានធុរៈមិនអាចចូលរួមប្រជុំបាន តំណាងដែលចូលរួមប្រជុំដំបូងត្រូវរាយការណ៍ និងប្រគល់សេចក្តីព្រាងអត្ថបទ ទៅតំណាងដូចបានកំណត់ខាងលើ ដែលត្រូវបានប្រជុំបន្ត ដើម្បីជៀសវាងលើកយកបញ្ហាដែលបានឯកភាពគ្នារួចហើយ មកពិភាក្សាម្តងទៀត ។

ដើម្បីត្រៀមការប្រជុំឱ្យបានល្អ ក្រសួង ស្ថាប័នសាមីត្រូវបញ្ជូនលិខិតស្នើសុំប្រជុំពិនិត្យសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត សម្រាប់អង្គប្រជុំលើកទី១ ក៏ដូចជាអង្គប្រជុំអន្តរក្រសួង និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ទៅស្តីការគណៈរដ្ឋមន្ត្រី ( អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល ) ដោយត្រូវភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម៖

- ច្បាប់ចម្លងសេចក្តីព្រាងអត្ថបទ ចំនួន ១២០ (មួយរយម្ភៃ) ច្បាប់ ឬច្រើនជាងនេះតាមការចាំបាច់ជាក់ស្តែង ដោយភ្ជាប់សូហ្វកូពី ( Soft Copy ) ផង។
- ច្បាប់ចម្លងនៃសេចក្តីថ្លែងហេតុ ចំនួន ១២០ (មួយរយម្ភៃ) ច្បាប់។
- ឯកសារពាក់ព័ន្ធ ដែលមានយោងនៅក្នុងមូលបទ ក្នុងមួយមុខៗ ចំនួន ២០ (ម្ភៃ) ច្បាប់ ។

ដើម្បីសម្រួលក្នុងការទាក់ទងការងារ សូមឯកឧត្តម លោកជំទាវ បញ្ជូនឈ្មោះមន្ត្រីទទួលបន្ទុក អាសយដ្ឋានទំនាក់ទំនង និងលេខទូរស័ព្ទ លេខទូរសារ ឬអ៊ីមែលទៅអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល (ជាន់ទី ២ បន្ទប់លេខ ២១២ ទូរស័ព្ទលេខ ០២៣ ២១៩ ១៦០ , ០១២ ៩៦៥ ១៤៦ , ០១១ ៩៤៥ ៨៥៣ ។

សូមឯកឧត្តម លោកជំទាវ មេត្តាជ្រាប និងអនុវត្តតាមការគួរ ។

សូមឯកឧត្តម លោកជំទាវ មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រ ពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**ចម្លងជូន**
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ឯកសារ-កាលប្បវត្តិ